№: 5
08-2-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥ លេខ ៥ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

LAM.

ក

មាតិកា

I . ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៤_០២_១៩៩៧_ ព្រះរាជក្រឹត្យ នស/រកត/២៩៧/០៩ ស្តីពីរូបភាពលំដាប់សក្តិរបស់កងយោធពលខេមរភូមិន្ទ ៣៤៥

II _ ទីស្តីការគណៈរដ្ឋមន្ត្រី

១_អនុក្រឹត្យ

០៥_០២_១៩៩៧_ អនុក្រឹត្យលេខ ១៤ អនក្រ ស្តីពីការបញ្ជាចំណាយឥតគ្រោងទុក មានលក្ខណៈចាំបាច់របស់ក្រសួងការពារជាតិ ៣៥១

III - ការិយាល័យក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

០៣–០២–១៩៩៧– ប្រកាសលេខ ០១៨ ក្រ.ក.ស.ហ.រ.ព.ម ស្តីពីការបង្កើតក្រុមការងារដើម្បីដឹកនាំការចាត់ចែងអនុវត្តច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ ១៩៩៧ ៣៥៣

០៦_០២_១៩៩៧_ ប្រកាសលេខ ០២០ សហវ.សប្រក ស្តីពីការអនុវត្តន៍លិខិតបញ្ជារបស់រាជរដ្ឋាភិបាល ៣៥៦

ខ

២_ ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

ប្រកាស

០៣_០២_១៩៩៧_ ប្រកាសលេខ ៩៣ ផក.ប្រក អនុញ្ញាតអោយលោក ស៊ុន ហុង ជនជាតិខ្មែរសញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម ៣៥៨

០៣_០២_១៩៩៧_ ប្រកាសលេខ ៩៤ ផក.ប្រក អនុញ្ញាតអោយលោក សុខ សេង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកក ៣៥៨

០៣_០២_១៩៩៧_ ប្រកាសលេខ ៩៥ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ឃុន ចារី ជាប្រធានមូលដ្ឋានផលិតទឹកកកដើម ផ្ទេរសិទ្ធិគ្រប់គ្រងជូនអ្នកស្រី ស៊ីវ ផល្លីន វិញ ៣៥៩

០៣_០២_១៩៩៧_ ប្រកាសលេខ ៩៦ ផក.ប្រក អនុញ្ញាតអោយលោក ឆេង ហ៊ិន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១២០សេះ ៣៥៩

០៣_០២_១៩៩៧_ ប្រកាសលេខ ៩៧ ផក.ប្រក អនុញ្ញាតអោយលោក សិត អ៊ិន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤សេះ ៣៦០

០៣_០២_១៩៩៧_ ប្រកាសលេខ ៩៨ ផក.ប្រក អនុញ្ញាតអោយលោក ទីវ លួ ជនជាតិខ្មែរសញ្ជាតិកម្ពុជា បន្តដំណើរការ រោងម៉ាស៊ីនកិនស្រូវកំលាំង ៥០សេះ ៣៦០

០៣_០២_១៩៩៧_ ប្រកាសលេខ ៩៩ ផក.ប្រក អនុញ្ញាតអោយលោក ហេង សុខា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១២០សេះ ៣៦១

ឥ

០៣_០២_១៩៩៧_ ប្រកាសលេខ ១០០ ផក.ប្រក អនុញ្ញាតអោយលោក ផាត ផានី ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០សេះ ៣៦១

០៣_០២_១៩៩៧_ ប្រកាសលេខ ១០១ ផក.ប្រក អនុញ្ញាតអោយរោងម៉ាស៊ីនផលិតទឹកកកដើម មានលោក គួច សុជា ជនជាតិខ្មែរ សញ្ញាតិកម្ពុជា ជាប្រធាន ៣៦២

០៣_០២_១៩៩៧_ ប្រកាសលេខ ១០២ ផក.ប្រក អនុញ្ញាតអោយសិប្បកម្មផលិតអិដ្ឋ_ក្បឿង មានលោក ព្រំ សុវណ្ណ ជនជាតិខ្មែរ សញ្ញាតិកម្ពុជា ជាប្រធាន ៣៦២

០៣_០២_១៩៩៧_ ប្រកាសលេខ ១០៣ ផក.ប្រក អនុញ្ញាតអោយលោក យ៉ុន ភាព ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវកំលាំង ១២០សេះ ៣៦៣

០៥_០២_១៩៩៧_ ប្រកាសលេខ ១០៤ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុនអន្តរជាតិខេមអូ (CAMEO INTERNATIONAL Co LTD) តំណាងដោយលោក ជា យុង ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញឈ្មោះថា «រោងចក្រកាត់ដេរអន្តរជាតិខេមអូ » ៣៦៣

០៥_០២_១៩៩៧_ ប្រកាសលេខ ១០៥ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុនសំហានខេមបូឌាហ្វ៊ែប្រ៊ិក (SAM HAN CAMBODIA FABRIC Co LTD) តំណាងដោយលោក KIM DO SAM សញ្ញាតិកូរ៉េ បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ «ឈ្មោះថា » សំហានខេមបូឌាហ្វ៊ែប្រ៊ិក ។ ៣៦៤

០៧_០២_១៩៩៧_ ប្រកាសលេខ ១០៦ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុនជូស៊ីងហ្គាមីន (ខាមបូឌា) អែលធីឌី (CAMBODIA LTD) តំណាងដោយលោក CHEN RON MING) សញ្ញាតិតៃវ៉ាន់

បង្កើតរោងចក្រកាត់ដេរនាំចេញ ដែលមានឈ្មោះថា «រោងចក្រ
ជូស៊ីង ហ្វាមិន» ៣៦៦

៣_ទីស្ដីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១_ សេចក្ដីសំរេច

០៤-០២-១៩៩៧- សេចក្ដីសំរេច ០៣៨ សលរ.កសក ស្ដីពីការបង្កើតគណៈកម្មការ
?៦ រៀបចំទិវានយោបាយទឹកកសិកម្ម

៤_ទីស្ដីការរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

១_សេចក្ដីសំរេច

០៤-០២-១៩៩៧- សេចក្ដីសំរេចលេខ ០៦៧ សក១ សសរ តែងតាំងសមាសភាព
បន្ថែមក្នុងគណកម្មការ ដើម្បីសិក្សាស្រាវជ្រាវ និងផ្ដល់យោបល់
លើឯកសារ PRELIMINARY DESIGN AUDIT ព្រមជាមួយ
DETAILEDPRO GRAMME GENERAL PLAN
PRELIMINARY BESIGN និងពង្រាងកិច្ចសន្យាបន្ថែមស្ដីពី
ការសាងសង់ព្រលានយន្ដហោះអន្ដរជាតិពោធិចិនតុង ៣៦៨

៥_ទីស្ដីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

០៣_០២_១៩៩៧_ ប្រកាសលេខ ០២៩/៩៧ ពម.ប្រក អនុញ្ញាតអោយចេញផ្សាយ
ទស្សនាវដ្ដី «ប្រិយមិត្ត » បោះពុម្ពចែកផ្សាយដោយមានលោក
ចាន់ វ៉ែន ជាចាងហ្វាងការផ្សាយ ៣៦៩

០៤_០២_១៩៩៧_ ប្រកាសលេខ ០៣០/៩៧ ពម.ប្រក អនុញ្ញាតអោយកាសែត
«យុត្តិធម៌ » បន្តការចេញផ្សាយរបស់ខ្លួនឡើងវិញដោយមាន
លោក វ៉ង សារឿន ជាចាងហ្វាងការផ្សាយ ៣៧១

០៦_០២_១៩៩៧_ ប្រកាសលេខ ០៣២/៩៧ ពម.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៧២

៦_ទីស្តីការរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

ប្រកាស

០៤–០២–១៩៩៧– ប្រកាសលេខ ០៦ ប្រក.បល ៩៧ លោក ហុង សុធី ជាប្រឡាបញ្ជីបំរើការងារនៅខេត្តស្វាយរៀង ត្រូវបានផ្ទេរអោយទៅបំរើការងារនៅតុលាការខេត្តកណ្តាល ៣៧៣
០៦_០២_១៩៩៧_ ប្រកាសលេខ ០៨ ប្រក.បប ៩៧ លោក តាត សុភាក់ ក្រឡាបញ្ជីតុលាការខេត្តកំពត ផ្ទេរអោយទៅបំរើការងារខេត្តកណ្តាល ៣៧៥
០៦_០២_១៩៩៧_ ប្រកាសលេខ ១០ ប្រកប.បប ៩៧ តែងតាំងលោក ចាន់ សុភាព បច្ចុប្បន្នជាបុគ្គលិកបំរើការងារនៅតុលាការខេត្តកំពង់ឆ្នាំង ជាក្រឡាបញ្ជីខេត្តកំពង់ឆ្នាំង ៣៧៥

៧_ ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

ប្រកាស

០៣_០២_១៩៩៧_ ប្រកាសលេខ ១១៩ អយក.ប្រក ស្តីពីការអនុញ្ញាតអោយបើកសាលាបឋមសិក្សា «សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ រាជានុកូល» ក្នុងដែនទីសិក្សា ខេត្តស្ទឹងត្រែង ៣៧៦
០៣_០២_១៩៩១_ ប្រកាសលេខ ១២០ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា «ឧត្តមសហគម» មកជាសាលាបឋមសិក្សា «ប៊ុន រ៉ានី ហ៊ុន សែន ឧត្តមសមាគម» ៣៧៩
០៤_០២_១៩៩៧_ ប្រកាសលេខ ១២៧ អយក.ប្រក ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅរូបវិទ្យា «សំរាប់សិស្សថ្នាក់ទី ៨» ៣៨១

៨_ ទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ប្រកាស

០៧_០២_១៩៩៧_ ប្រកាសលេខ ០២៨ បទ.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ

៩_ ទីស្តីការក្រសួងធម្មការ និងសាសនា

១_សេចក្តីសំរេច

០៣_០២_១៩៩៧_ សេចក្តីសំរេចលេខ ១៩/៩៧ កធស អនុញ្ញាតជាគោលការណ៍ អោយបើកស្នាក់ការថ្វាយបង្គំព្រះគ្រីស្ទ និកាយប្រូតេស្តង់ ក្រុមជំនុំមេត្រីភាពកម្ពុជា នៃវិហារឈ្មោះ «ក្រុមជំនុំមេត្រីភាពពោធិចិនតុង» សង្កាត់កាកាប ខ័ណ្ឌដង្កោ ភ្នំពេញ ៣៨២
០៣_០២_១៩៩៧_ សេចក្តីសំរេចលេខ ២០/៩៧ កធស អនុញ្ញាតជាគោលការណ៍ អោយបើកស្នាក់ការថ្វាយបង្គំព្រះគ្រីស្ទនិកាយប្រូតេស្តង់ «ក្រុមប្រិសប៊ីតំរៀត» នៃវិហារឈ្មោះ «គ្រីស្ទបរិស័ទគ្រប់ជនជាតិក្រុងភ្នំពេញ» នៅសង្កាត់ផ្សារថ្មីទី ១ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ៣៨៦
០៤_០២_១៩៩៧_ សេចក្តីសំរេចលេខ ២១/៩៧ កធស អនុញ្ញាតជាបណ្តោះអាសន្ន អោយបើក «ពុទ្ធិកសមាគមអភិវឌ្ឍកម្ពុជា» ៣៨៦

២_ប្រកាស

០៦_០២_១៩៩៧_ ប្រកាសលេខ ២៣/៩៧ កធស.ប្រក តែងតាំងលោក ទេព ធន បច្ចុប្បន្នអនុប្រធានមន្ទីរធម្មការ និងសាសនាជាប្រធានមន្ទីរធម្មការ និងសាសនាជំនួសលោក មោក ស៊ីម ៣៨៧

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/០២៩៧/០៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត ចិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ស្តីពីរូបភាព និងឋានុតលំដាប់ថ្នាក់ក្នុងកងទ័ពជាតិកម្ពុជា ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការបង្កើតអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ ជស/រកត/ ១២៩៤/១៨ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៧ ស្តីពីការបង្កើតក្រសួងការពារជាតិ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញសំណើរបស់នាយករដ្ឋមន្ត្រីទាំងពីរ និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ត្រាស់បង្គាប់

មាត្រា ១ : រូបភាពលំដាប់សក្តិរបស់កងយោធពលខេមរភូមិន្ទត្រូវបានកំណត់ដូចខាងក្រោម÷

- អំពីរូបភាពសក្តិ :

ក- សក្តិថ្នាក់ឧត្តមសេនីយ៍មាន ៣ ប្រភេទគឺ :

១–សក្តិស្នាសំរាប់ថ្ងៃបុណ្យជាតិ ពិធីការកិត្តិយស សំរាប់ពាក់ជាមួយឯកសណ្ឋានលេខ១ (អាវកុដ ស)រូបភាពសក្តិមានរាងទ្រវែង ផ្ទៃធ្វើអំពីក្រណាត់កាំម៉ឺ ពណ៌មាស ផ្កាយពណ៌មាស ជាសញ្ញាសំគាល់សក្តិថ្នាក់ឧត្តមសេនីយ៍ រូបម្កុដទ្រព្រះខ័ន ពណ៌មាស និងខ្សែរូបព្រះសង្ការពណ៌មាស ។

–វិមាត្រ :

–បណ្តោយប្រវែង	១៣.៥. ស.ម
–ទទឹងខាងដើមប្រវែង	៦. ស.ម
–ទទឹងខាងចុងបញ្ឆិតមុខកាត់ត្រង់	២.៥. ស.ម
–ពីខាងដើមដល់ផ្កាភ្ញីប្រវែង	០.៥. ស.ម
–ក្បាចផ្កាភ្ញីទទឹងប្រវែង	១. ស.ម
–ចន្លោះសំរាប់ដាក់ផ្កាយ	៦.៣ ស.ម
–ទំហំម្កុដ និងព្រះខ័នទ្រ	៣.២ ស.ម
–ខ្សែមានរូបព្រះសង្ការ បន្ទាត់ផ្ចិតប្រវែង	១.៥ ស.ម
–ពីចុងមកខ្សែមានប្រវែង	១.០ ស.ម

– របៀបដាក់ផ្កាយលើសក្តិស្នា :

– ថ្នាក់ឧត្តមសេនីយ៍ត្រី មានផ្កាយពណ៌មាសមួយ រៀបឃ្លាតពីផ្កាភ្ញីប្រវែង ១.២សម ចំកណ្តាល ។

– ឧត្តមសេនីយ៍ទោ មានផ្កាយពណ៌មាសពីរ រៀបទន្ទឹមគ្នា កាត់ទទឹងសក្តិ ឃ្លាតពីផ្កាភ្ញី ១.២ សម ។

– ឧត្តមសេនីយ៍ឯក មានផ្កាយពណ៌មាសបី រៀបផ្កាយរាងត្រីកោណ (តាមកន្លែងផ្កាយមួយពីរ) ។

– ឧត្តមសេនីយ៍អគ្គទ័ព មានផ្កាយមាសបួន រៀបជារាងការេ ស្ទាបព្រួញបួនជ្រុង

– ឧត្តមសេនីយ៍ផុតលេខ មានផ្កាយមាសប្រាំ រៀបផ្កាយដូចផ្កាយបួន តែបន្ថែមមួយទៀតពីខាង លើផ្កាយមានរង្វាស់ផ្ចិត ១.៨ សម កំពស់ផ្កាយមានប្រវែង ០.៦សម ។

២– សក្តិស្នាថ្នាក់ឧត្តមសេនីយ៍សំរាប់ពិធីការជាតិ អន្តរជាតិទទួលគណៈប្រតិភូបរទេស និង ធ្វើការក្នុងការិយាល័យ ជាទូទៅសំរាប់ពាក់ជាមួយ ឯកសណ្ឋានធំពណ៌កាគី (អាវវ៉ារី ឯកសណ្ឋានលេខ២ និង ឯកសណ្ឋានលេខ ៣ (សាហារីយ៉ែន)

ឯសណ្ឋានលេខ ៤ (ការងារ) រូបភាពសក្តិមានរាងទ្រវែងចុងស្រួច ធ្វើអំពីក្រណាត់កាំម្ទី ពណ៌ខ្មៅ ផ្កាយ ខ្សែ ក្បាច់ ផ្កាភ្ញី រូបមកុដ ព្រះខ័នទ្រ ពណ៌មាស ។

—អំពីខ្នាត :

–បណ្តោយប្រវែង	១៣.៥ សម
–ទទឹងខាងដើម	៦.០ សម
–ទទឹងខាងចុងចំណុចកាច់ទៅចុងស្រួច	៤.០ សម
–ពីខាងដើមសក្តិដល់ផ្កាភ្ញីប្រវែង	០.៥ សម
–ទទឹងក្បាច់ផ្កាភ្ញីប្រវែង	១.០ សម
–ចន្លោះប្រដាប់ដាក់ផ្កាយប្រវែង	៦.៣ សម
–មកុដ និង ព្រះខ័នមានទំហំ	៣.២ សម
–ខ្សែមានរូបព្រះសង្ហារ បន្ទាត់ផ្ចិត	១.៥ សម
–ពីខ្សែទៅស្រួចសក្តិ	១.០ សម

៣–អំពីសក្តិឧត្តមសេនីយ៍ សំរាប់ប្រតិបត្តិការសឹកសំរាប់ពាក់នៅ កអាវឆ្វេង លើឯកសណ្ឋានប្រយុទ្ធ :

—រូបភាពសក្តិ :

១– ឧត្តមសេនីយ៍ត្រី ទំហំហ្មុងសក្តិ ពណ៌ខ្មៅ បណ្តោយ ៣.៣សម ទទឹង ២.៣ សម ផ្កាយពណ៌មាស មាន ១ ចំកណ្តាល បន្ទាត់ផ្ចិតនៃរង្វង់ផ្កាយ ១.២សម ។

២– ឧត្តមសេនីយ៍ទោ ទំហំហ្មុងសក្តិ និងផ្កាយដូចឧត្តមសេនីយ៍ត្រី តែផ្កាយពណ៌មាស ២ រៀបទន្ទឹមគ្នា ចំកណ្តាល ។

៣–ឧត្តមសេនីយ៍ឯក ទំហំហ្មុងសក្តិ និងផ្កាយដូចឧត្តមសេនីយ៍ត្រីតែផ្កាយពណ៌មាស៣រៀបត្រីកោណ ។

៤– ឧត្តមសេនីយ៍អង្គទ័ព ទំហំហ្មុងសក្តិ និងផ្កាយដូចឧត្តមសេនីយ៍ត្រី តែផ្កាយពណ៌មាស ៤រៀប រាងចតុកោណស្មើបញ្ឈរជ្រុង ។

៥–ឧត្តមសេនីយ៍ផុតលេខ ទំហំហ្មុងសក្តិពណ៌ខ្មៅ បណ្តោយ ៣.៦សម ទទឹង ២៣សម ផ្កាយមាស៥ រៀប ៣ បណ្តោយ ២ទទឹង ទំហំរង្វង់ផ្កាយដូចខាងលើ ។

ខ–សក្តិថ្នាក់វរសេនីយ៍ អនុសេនីយ៍និងនាយទាហានរងថ្នាក់ទី១ៈ មាន៣ ប្រភេទគឺ :

១–សក្តិសំរាប់ថ្ងៃបុណ្យជាតិ ដូចឧត្តមសេនីយ៍ ។

២–សក្តិពិធីការ និងធ្វើការងារ សំរាប់ពាក់លើឯកសណ្ឋាន ធំលេខ ២ ពណ៌កាគី ឯកសណ្ឋានធំ លេខ ៣ (សាហារីយ៉ែន) និងឯកសណ្ឋានការងារធ្វើពីក្រណាត់ ាំម្ញី ពណ៌ខ្មៅ រាងទ្រវែង ចុងស្រួច ឆ្នូតសក្តិកាត់ទទឹង ខ្សែវម្អុជ ព្រះខ័នពណ៌មាស ។ ចំណែកសក្តិថ្នាក់ វរសេនីយ៍ទោ មានឆ្នូតពីរកាត់ទទឹង ពណ៌ទឹកប្រាក់ (ទី ២-៤) និងបីទៀតពណ៌មាស ។

–ទំហំខ្នាត :

–បណ្តោយប្រវែង ១៣.៥ សម

–ទទឹងដើម ៦.០ សម

–ទទឹងខាងចុងប្រវែង ៤.០ សម

–ឆ្នូតសក្តិទទឹងប្រវែង ០.៨ ស.ម បណ្តោយស្មើទទឹង រៀបឃ្លាតពីខាងដើមសក្តិ ១ ស.ម ។

–ឆ្នូតសក្តិនីមួយៗ ឃ្លាតពីគ្នាប្រវែង ០.២ សម ដោយឡែកវរសេនីយ៍ ឆ្នូតទី៣ ទៅឆ្នូតទី៤ ឃ្លាត ពីគ្នា ០.៧ សម ។

របៀបរៀបចំរូបភាពសក្តិ :

–វរសេនីយ៍ឯក មានឆ្នូត ពណ៌មាស ៥

–វរសេនីយ៍ទោ មានឆ្នូត ពណ៌មាស ៣ និងឆ្នូត ពណ៌ស ២

–វរសេនីយ៍ត្រី មានឆ្នូត ៤ ពណ៌មាស

–អនុសេនីយ៍ឯក មានឆ្នូត ៣ ពណ៌មាស

–អនុសេនីយ៍ទោ មានឆ្នូត ២ ពណ៌មាស

–អនុសេនីយ៍ត្រី មានឆ្នូត ១ ពណ៌មាស

–សក្តិស្មានាយចំណង់ឆ្នូត១ ពណ៌មាស ទំហំទទឹង ០.៨ សម មានឆ្នូតខ្មៅ២ កាត់ទំហំ ០.១ សម ។

–សក្តិស្មាព្រិន្ទបាលឯក ឆ្នូតមានតែមួយ ពណ៌មាស ទំហំទទឹងឆ្នូតសក្តិ ០.៨ សម នៅចំកណ្តាលហើយ បណ្តោយ ឆ្នូតសក្តិ មានគូសគំនូសក្រហមមួយ ។

Á±Þគសក្តិយស្សះ ព្រិន្ទបាលទោ ឆ្នូតមានតែមួយ ពណ៌ទឹកប្រាក់ ទំហំទទឹងឆ្នូតសក្តិ ០.៨ សម នៅចំកណ្តាល ហើយបណ្តោយឆ្នូតសក្តិ មានគូសគំនូសក្រហមមួយ ។

៣—សក្តិសំរាប់ប្រតិបត្តិការសឹក៖ សំរាប់នៅលើកអាវឆ្វេងឯកសណ្ឋានប្រយុទ្ធ ។

–ផ្ទៃហុងសក្តិពណ៌ខ្មៅ ពាក់ប.ណ្តោយបញ្ឈរឡើងលើ បណ្តោយប្រវែង ៣.៤ សម ទទឹង២.៨សម ។

—ចំពោះការរៀបចំសក្តិ : រៀបតាមលំដាប់ពីក្រោមមកលើ ហើយរៀបចំស្ថិតនៅកណ្តាលហុងសក្តិ ឆ្នូតសក្តិប្រវែង ២.២ សម ទទឹងឆ្នូត ០.២៥ សម ចន្លោះពីឆ្នូតមួយទៅមួយប្រវែង ០២សម ដោយឡែកថ្នាក់ វរសេនីយ៍ ឆ្នូតទី៣ ទៅឆ្នូតទី៤ ឃ្លាតគ្នាប្រវែង ០.៥សម ពណ៌មាស ។ ចំពោះវរសេនីយ៍ទោ ឆ្នូតទី២ និង ទី៤ ពណ៌ស ។ ព្រិន្ទបាលឯក ឆ្នូតពណ៌មាស ចំកណ្តាល និងបណ្តោយឆ្នូត មានគូសគំ[illegible]ក្រហម ។ ព្រិន្ទបាលទោ ឆ្នូតពណ៌មាស ចំកណ្តាល និងបណ្តោយឆ្នូត មានគូសគំ[illegible] ។

គ—សក្តិនាយទាហានរងថ្នាក់ទី២ (ជាន់ទាប) និងពលទាហាន :

ចំពោះសក្តិពាក់ចូលរួមក្នុងពិធីការ ឬធ្វើការងារក្នុងការិយាល័យ នៅលើស្មាពាក់តែហុងសក្តិ មានមុងទ្រដោយព្រះខ័នតែប៉ុណ្ណោះ ។ ចំពោះសក្តិរបស់នាយទាហានរងថ្នាក់ទី២ និងពលទាហាន នៅដៃអាវ ឆ្វេងចុះពីថ្នេរស្មាចំនួន ០.៥ សម ។

រំលឹកខ្នាត :

–បណ្តោយប្រវែង ៩.៥ សម
–ទទឹងខាងលើ ៦.០ សម ចុងស្រួច
–បណ្តោយមកដល់មុំស្រួច ៦.៥ សម ដាក់ឃ្លាតពីចុងលើ ០.៦ ស.ម
–ទំហំមុងព្រះខ័នទ្រ ៣.២ សម

រំលឹកសក្តិ :

នាយទាហានរងថ្នាក់ទី២ :

–ពលបាលត្រី ឆ្នូតកាត់ ០១ ពណ៌មាស
–ពលបាលទោ ឆ្នូតកាត់ ០២ ពណ៌មាស
–ពលបាលឯក ឆ្នូតកាត់ ០៣ ពណ៌មាស

ពលនាវាចរ :

-ពលទោ មានតែហ៊ុងសក្តិស្វា ហើយនៅលើហ៊ុងមានម្កុដព្រះខ័នទ្រ ប៉ុណ្ណោះ ។

-ពលឯក ឆ្នូតកាត់ ០១ ពណ៌ក្រហម

-នាយទោ ឆ្នូតកាត់ ០២ ពណ៌ក្រហម

-នាយឯក ឆ្នូតកាត់ ២ ខាងក្រោម ពណ៌ក្រហម ឆ្នូតកាត់ ១ ខាងលើ ពណ៌មាស ។

រូបភាពសក្តិទាំងអស់ រៀបចាប់ពីចុងស្រួចខាងក្រោមឡើងទៅលើ ហើយ កាច់ចុងស្រួចចុះ ក្រោមឆ្នូតនិមួយៗ ឃ្លាតពីគ្នា ០.២ សម ។

+សំគាល់ពលប្រតិបត្តិការសឹក :

សក្តិសំរាប់ពាក់នៅលើ កអាវ ឯកសណ្ឋានប្រយុទ្ធមួយប៉ុណ្ណោះ ដែលមាន ខ្នាតដូចខាងក្រោម ÷

-ផ្ទៃហ៊ុងធ្វើរាងជាខែល ស្រួចចុងមកក្រោម :

-បណ្តោយ គិតមកចុងស្រួចខាងក្រោម ប្រវែង ៣.៨ សម

-ទទឹងខាងលើ ២.៨ សម

-ទំហំម្កុដព្រះខ័នទ្រ កំពស់ ១.៨ សម ទទឹង ១.៥ សម

-សក្តិរៀបតាមលំដាប់លំដោយ ដូចសក្តិស្វា ពិធីការ+ការិយាល័យ ប៉ុន្តែ សក្តិប្រតិបត្តិការនេះ តូចជាង មានទំហំដូចខាងក្រោម ÷

+ទទឹងគំនូស ០.២៥ សម

+មុំកាច់របស់ឆ្នូត ១០០ សេ

+ចុងម្ខាងទៅម្ខាង ២.៤ សម

+រៀបឃ្លាតពីគ្នារវាងឆ្នូតនិមួយៗ ០.២ សម

ឃ-សក្តិកងនាវាចរភូមិន្ទកម្ពុជា និងកងអាកាសចរភូមិន្ទកម្ពុជា :

សក្តិរបស់កងនាវាចរភូមិន្ទកម្ពុជា និងកងអាកាសចរភូមិន្ទកម្ពុជា ដូចគ្នានិង កងទ័ពជើងគោកដែរ គ្រាន់តែមានផ្លាស់ប្តូរ :

-កងនាវាចរភូមិន្ទកម្ពុជា ខាងក្រោមម្កុដ ដាក់រូបយុថ្កាទ្រម្កុដ ពណ៌មាស

–កងអាកាសចរភូមិន្ទកម្ពុជា ខាងក្រោមម្ជុល ដាក់រូបស្លាបសត្វទ្រម្ជុល ពណ៌មាស

មាត្រា ២ : រាល់ការផលិតសក្តិខុសពីរូបភាពខាងលើ ដែលកំណត់ក្នុងមាត្រា ១ ត្រូវបានហាមឃាត់ ។ នាយទាហាន និងពលទាហាននៃកងយោធពលខេមរភូមិន្ទ ត្រូវប្រើប្រាស់ត្រឹមត្រូវតាមការកំណត់ ។

មាត្រា ៣ : រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះ ។

មាត្រា ៤ : ក្រឹត្យនេះចូលជាធរមាន ចាប់ពីពេលឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

ព្រះហស្ថលេខា

នរោត្តម សីហនុ

បង្គំទូលថ្វាយ និងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ទៀ បាញ់ , នា ចាយ៉ាត់

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្ថលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

II - ឯកសារគណៈរដ្ឋមន្ត្រី

១_អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ១៤ អនក្រ .បក

ស្តីពីការបញ្ជាចំណាយឥតគ្រោងទុកមានលក្ខណៈចាំបាច់

របស់ក្រសួងការពារជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស.រកម ១២៩៦.៣៧ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៦
- **យោងតាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
- **យោងតាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល**

សំរេច

មាត្រា ១ : កំណត់អោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោះស្រាយថវិកាសំរាប់ចំណាយឧបត្ថម្ភកំលាំងខ្មែរក្រហម ផ្តាច់ខ្លួនដែលបានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលដូចខាងក្រោម :

0ÁÂâp

ក–អនុញ្ញាតផ្តល់ថវិកាចំនួន ៩៤៨.៧៨០.០០០រៀល សំរាប់ទិញអង្ករ ១.២៥៥តោន ពីប្រទេសថៃ ដើម្បីផ្គត់ផ្គង់កំលាំងខ្មែរក្រហមផ្តាច់ខ្លួនដែលបានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលរយៈពេល បីខែដោយគិតពីខែ ធ្នូ ឆ្នាំ ១៩៩៦ ដល់ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ។

ខ–អនុញ្ញាតផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែ ប្រាក់អាហារ ប្រាក់ម្ហូប អោយដល់កំលាំងខ្មែរក្រហមផ្តាច់ខ្លួន ដែលបានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាល រយៈពេលបីខែ

ដោយគិតពីខែ ធ្នូ ឆ្នាំ ១៩៩៦ ដល់ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ទៅតាមរបបកំណត់របស់កងយោធពលខេមរភូមិន្ទ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសហរដ្ឋមន្ត្រី ក្រសួងការពារជាតិត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ អោយបានសំរេច ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខា និងត្រា ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

III - ការងារបណ្តាក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ០១៨ ប្រក.សហវ.ពដ

ស្តីពីការបង្កើតក្រុមការងារ ដើម្បីដឹកនាំ

ការចាត់ចែងអនុវត្តន៍ច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះ រាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស.រកម ០១៩៦.១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសំណើរបស់ប្រធាននាយកដ្ឋានពន្ធដារ

សម្រេច

ប្រការ ១ : ត្រូវបានបង្កើតក្រុមការងារមួយ ដើម្បីដឹកនាំការចាត់ចែងអនុវត្តន៍ច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧ ដែលមានសមាសភាពដូចខាងក្រោម :

១– ឯកឧត្តម	ជា ប៉េងឈាង	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ប្រធាន
២– ឯកឧត្តម	សាភ៊ក់ ខាន់	អគ្គនាយកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	អនុប្រធាន
៣–លោក	ហុង ចា	ប្រធាននាយកដ្ឋានពន្ធដារ	សមាជិក
៤–លោក	ចាន់ ស៊ី	អនុប្រធាននាយកដ្ឋានពន្ធដារ	សមាជិក
៥–លោក	កែវ សាវុន	អនុប្រធាននាយកដ្ឋានពន្ធដារ	សមាជិក
៦–លោក	អ៊ុល វណ្ណធី	ប្រធានការិយាល័យអង្កេតនិងផ្តុំពត៌មាន	សមាជិក
៧–លោក	អ៊ុំ សីហា	ប្រធានអង្គភាពនយោបាយសារពើពន្ធ	សមាជិក
៨–លោក	ភិន់ ពុទ្ធិពល	អនុប្រធានការិយាល័យនីតិកម្មសារពើពន្ធ	លេខាសរុប

ប្រការ ២ : ក្រុមការងារនេះត្រូវបង្កើតផ្នែកជំនួយការចំនួន៦ ដែលមានសមាសភាពនិងភារកិច្ចដូចខាងក្រោម :

I–ផ្នែកជ្រើសរើស និងចាត់ចែងបុគ្គលិក :

១–លោក	យស់ ស៊ីម៉ាភិត	ប្រធានការិយាល័យបុគ្គលិក	ប្រធាន
២–លោក	មឿង ម៉ាណេត	អនុប្រធានការិយាល័យបុគ្គលិក	សមាជិក

II—ផ្នែករៀបចំសេចក្តីជូនដំណឹងនិងផ្សព្វផ្សាយ :

១–លោក អ៊ុល វណ្ណធី ប្រធានការិយាល័យអង្កេតនិងផ្តុំពតិមាន ប្រធាន

២–លោក ស្រី វណ្ណា ប្រធានការិយាល័យប្រមូលពន្ធតាមរបបពិត សមាជិក

III—ផ្នែកជំរឿនអ្នកជាប់ពន្ធលើប្រាក់បៀវត្ស :

១–លោក អ៊ុល វណ្ណធី ប្រធានការិយាល័យអង្កេតនិងផ្តុំពតិមាន ប្រធាន

២–លោក ជូ ស្រ៊ុន អនុប្រធានការិយាល័យអង្កេតនិងផ្តុំពតិមាន សមាជិក

៣–លោក ម៉ុញ សារ៉ន អនុប្រធានការិយាល័យអង្កេតនិងផ្តុំពតិមាន សមាជិក

៤–លោក ឃុន សារឿន អនុប្រធានការិយាល័យប្រមូលពន្ធតាមរបបពិត សមាជិក

៥–លោក ប៉ុល ប៊ុនរ៉ុងរឿង អនុប្រធានការិយាល័យត្រួតពិនិត្យសារពើពន្ធ សមាជិក

VI—ផ្នែកនីតិកម្ម :

១–លោក អ៊ុន សំបុក អនុប្រធានការិយាល័យនីតិកម្មសារពើពន្ធ ប្រធាន

២–លោក វ៉ាន់ ពុទ្ធិពល អនុប្រធានការិយាល័យនីតិកម្មសារពើពន្ធ សមាជិក

៣–លោកស្រី មឿង គីមណៃ អនុប្រធានក្តាប់រួមការិយាល័យនីតិកម្មសារពើពន្ធ សមាជិក

៤–លោកស្រី អ៊ុង សូនី អនុប្រធានការិយាល័យប្រមូលពន្ធតាមរបបពិត សមាជិក

៥–លោក ទឹម ប៉េត ប្រធានការិយាល័យវិវាទ សមាជិក

៦–លោក ជា ពិសិដ្ឋ អនុប្រធានការិយាល័យវិវាទ សមាជិក

៧–លោក ឆឹង វ៉ាន់ថូ អនុប្រធានការិយាល័យពិនិត្យបញ្ជាក់សហគ្រាស សមាជិក

៨–លោក គីម វិចិត្រ មន្ត្រីការិយាល័យនីតិកម្មសារពើពន្ធ សមាជិក

V—ផ្នែករៀបចំទម្រង់និងបែបបទសំរាប់អនុវត្ត :

១–លោក កែវ ប៊ុនសួ ប្រធានការិយាល័យចាត់ចែង ប្រធាន

២–លោក សេង លី អនុប្រធានការិយាល័យចាត់ចែង សមាជិក

៣–លោក ចាត់ គីមសែ មន្ត្រីការិយាល័យប្រមូលពន្ធតាមរបបពិត សមាជិក

៤–លោក ហួង សុផាន មន្ត្រីការិយាល័យប្រមូលពន្ធតាមរបបពិត សមាជិក

៥-លោក ចាន់ ពិសិដ្ឋ មន្ត្រីការិយាល័យបុគ្គលិក សមាជិក

VI–ផ្នែកកុំព្យូទ័រនិងទូរគមនាគមន៍ :

១-លោក សន ស៊ីម ប្រធានការិយាល័យពត៌មានវិទ្យា ប្រធាន

២-លោក អៀម សំអុល អនុប្រធានការិយាល័យពត៌មានវិទ្យា សមាជិក

៣-លោក ពេជ្រ ច័ន្ទតារា អនុប្រធានការិយាល័យប្រមូលពន្ធតាមរបបពិត សមាជិក

ប្រការ ៣ : សមាជិកនៃក្រុមការងារនេះ ត្រូវបំពេញភារកិច្ច និងចូលរួមប្រជុំនៅរៀងរាល់ល្ងាចថ្ងៃច័ន្ទ វេលាម៉ោង ១៤ និង ៣០នាទី នៅបន្ទប់ប្រជុំនៃនាយកដ្ឋានពន្ធដារ និងត្រូវធ្វើរបាយការណ៍ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅរាល់ចុងខែនិមួយៗ ។

ប្រការ ៤ : អគ្គនាយក នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពន្ធដារ និង អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនក្នុងប្រការ១ និងប្រការ២ ខាងលើត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ហត្ថលេខា និងត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩

ប្រកាសលេខ : ០២០ សហវ.សប្រក

ស្តីពីការអនុវត្តលិខិតបញ្ជារបស់រាជរដ្ឋាភិបាល

* * *

– យោងតាមលិខិតបញ្ជាលេខ ៣៧សជណ.លប ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៦ និងសេចក្តីប្រកាសលេខ ០២សប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៦ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការប្រកាសបិទទាំងស្រុងការនាំចេញឈើហ៊ុប និងឈើអារ ចាប់ពីថ្ងៃទី៣១ ធ្នូ ១៩៩៦តទៅ

– ដើម្បីអនុវត្តអោយមានប្រសិទ្ធភាពនូវរាល់សេចក្តីប្រកាសនិងលិខិតបញ្ជារបស់រាជរដ្ឋាភិបាល

– ដោយបានឃើញមានករណីនៃឈើហ៊ុបមូល និងឈើអារដែលបានដឹកជញ្ជូនដល់ទីលានសុវត្ថិភាព ស្ថិតនៅតំបន់ព្រំដែនក្នុងទឹកដីថៃ

– ដើម្បីអោយមានតម្លាភាពក្នុងការប្រមូលថវិកាជូនជាតិ

– ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមចេញសេចក្តីប្រកាសចំពោះបណ្តាក្រុមហ៊ុនដែលបានទទួលការអនុញ្ញាតជាគោលការណ៍នាំចេញឈើ ពីរាជរដ្ឋាភិបាលកម្ពុជា បានជ្រាបដូចតទៅ :

១– បណ្តាក្រុមហ៊ុនដែលមានករណីឈើដូចពោលខាងលើ ត្រូវមកប្រកាសរាយការណ៍អំពីបរិមាណប្រភេទឈើ និងទីតាំងស្តុកឈើនៅទីលានសុវត្ថិភាព ស្ថិតនៅតំបន់ព្រំដែនក្នុងទឹកដីថៃ ។

២– ត្រូវចុះកិច្ចសន្យាស្តីពីការទិញ-លក់ឈើ ដែលបានដឹកជញ្ជូនដល់ទីលានសុវត្ថិភាពស្ថិតនៅតំបន់ព្រំ ដែនក្នុងទឹកដីថៃ ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។

៣– ការទូទាត់ត្រូវធ្វើឡើងតាមរយៈលិខិតឥណទាន សំរាប់ជាគុណប្រយោជន៍ដល់ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ ។ ក្រុមហ៊ុនទាំងឡាយត្រូវបើកលិខិតឥណទាន (Lettre de crédit stand-by, irrévo-cable) ដោយមានការអះអាងពីធនាគារជាទីទុកចិត្ត ។ ចំនួនប្រាក់ដែលទូទាត់ត្រូវបញ្ជូនទៅក្នុង គណនីរបស់ធនាគារជាតិ :

C/C No ០២១០-៨៧៣០-3 Federal Reserve Bank of New York , N.Y.33 Liberty Street,
Telex : MC 62 830 Answerback FEDRES/66 364 Answerback FEDRES UW.

៤– ក្រុមជំនាញនៃសមត្ថកិច្ចរុក្ខា និងសមត្ថកិច្ចគយនិងរដ្ឋាករនឹងត្រូវបានចាត់បញ្ជូនដល់ទីកន្លែងជាក់ស្តែង ដើម្បីធ្វើការត្រួតពិនិត្យ និងវាយតំលៃអំពីបរិមាណប្រភេទ និងគុណភាព ។

អាស្រ័យហេតុនេះ សូមបណ្តាក្រុមហ៊ុនដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះ ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា និងត្រា
គាត ឈន់

២_ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ៩៣ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

* * *

ប្រការ១ : អនុញ្ញាតអោយលោក ស៊ុន ហុង ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៥៤២២៩៦ ក.ណ ចុះថ្ងៃទី១៧-១២-៨៦ អាស័យដ្ឋានបច្ចុប្បន្ន ភូមិព្រែកធំ ឃុំក្បាលកោះ ស្រុកកៀន ស្វាយ ខេត្តកណ្ដាល បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម នៅក្នុងភូមិព្រែកធំ ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

ប្រការ២ : ប្រកាសនេះមានតម្លៃក្នុងរយៈបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៩៤ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

* * *

ប្រការ១ : អនុញ្ញាតអោយលោក សុខ ហេង ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣២៧០៨៣ ក.ណ ចុះថ្ងៃទី២៦-៣-៩១ អាស័យដ្ឋានបច្ចុប្បន្នភូមិស្ដៅកន្ទែង ឃុំជីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើមនៅក្នុងទីតាំងភូមិស្ដៅកន្ទែង ឃុំជីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

ប្រការ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថានប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៩៥ ផក.ប្រក ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៧

* * *

ប្រការ១ : អនុញ្ញាតអោយអ្នកស្រី ឃុន ធារី ជាប្រធានមូលដ្ឋាន ផលិតទឹកកកដើម ដែលមានទីតាំង ពីឡូត៍ លេខ២១ ផ្លូវលេខ៥៧០ ក្រុមទី៨១ សង្កាត់បឹងកក់ទី២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ផ្ទេរសិទ្ធិ កាន់កាប់ និងគ្រប់គ្រងជូនអ្នកស្រី ស៊ីវ ផល្លីន វិញ ។

ប្រការ២ : ទទួលស្គាល់អ្នកស្រី ស៊ីវ ផល្លីន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១១៤៥១៣ ភព ចុះថ្ងៃទី៣០-៤-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២ បេអឺ០ ផ្លូវលេខ១៦៤ ក្រុមទី៤១ សង្កាត់អូឫស្សីទី៣ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ ជាម្ចាស់មូលដ្ឋានផលិតទឹកកកដើម ដែលមានទីតាំង ដូចមានចែងក្នុងប្រការ១ ។

ប្រការ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាលដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៩៦ ផក.ប្រក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

* * *

ប្រការ១ : អនុញ្ញាតអោយលោក ឆេង ហ៊ាន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០១៧៧០ ប.ប ចុះថ្ងៃទី១៥-១-៨៦ អាស័យដ្ឋានបច្ចុប្បន្ន ភូមិថ្មគោល ឃុំតាម៉ឺន ស្រុកបាត់ដំបង ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១២០សេះ នៅក្នុងទីតាំងភូមិថ្មគោល ឃុំ តាម៉ឺន ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ប្រការ២ : លោក ឆេង ហ៊ាន ត្រូវបន្តដំណើរផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបាន កំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ភាគរយ ។

ប្រការ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៩៧ ផក.ប្រក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

* * *

ប្រការ១ : អនុញ្ញាតអោយលោក សារិត អិន ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៥៥៣២៨ ប.ប ចុះថ្ងៃទី១៧-៩-៨៨ អាស័យដ្ឋានបច្ចុប្បន្ន ភូមិពពាលខែ ឃុំអូរតាគី ស្រុកបាត់ដំបង ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង២៤សេះ នៅក្នុងទីតាំងភូមិពពាលខែ ឃុំ អូរតាគី ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ប្រការ២ : លោក សារិត អិន ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៩៨ ផក.ប្រក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

* * *

ប្រការ១ : អនុញ្ញាតអោយលោក ទីវ លូ ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣០១៩៤៩ ប.ប ចុះថ្ងៃទី១៨-១០-៩៣ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី៨ ភូមិព្រៃ ឃុំព្រៃ ស្រុកបាត់ដំបង ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង៥០សេះ នៅក្នុងទីតាំងក្រុមទី៨ភូមិព្រៃ ឃុំព្រៃ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ប្រការ២ : លោក ទីវ លូ ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ភាគរយ ។

ប្រការ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើស

ច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណង ឡើយ ។

* * *

ប្រកាសលេខ ៩៩ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

* * *

ប្រការ១ : អនុញ្ញាតអោយលោក ហេង សុខា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់លិខិតលេខ ៦៣៣ ឃសប ចុះថ្ងៃទី១០-៨-៨៦ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ២០ឧសភា ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង១២០សេះ នៅក្នុងទីតាំងភូមិអូរពងមាន់ ឃុំ តាក្រាម ស្រុកបាណន់ ខេត្តបាត់ដំបង ។

ប្រការ២ : លោកហេង សុខា ត្រូវចាប់ផ្ដើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសឬបង្កអោយមានការ ប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១០០ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

* * *

ប្រការ១ : អនុញ្ញាតអោយលោក ជាត ផានី ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៣០១២ កស៤ ចុះថ្ងៃទី២២-០១-៨៦ អាស័យដ្ឋានបច្ចុប្បន្ន ភូមិជ្រៃជើង ឃុំជ្រៃ ស្រុកមោងឫស្សី ខេត្តបាត់ដំបង បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង៤០សេះ នៅក្នុងទីតាំងភូមិជ្រៃជើង ឃុំជ្រៃ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។

ប្រការ២ : លោក ជាត ជាទី ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចមានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៨ ភាគរយ ។

ប្រការ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១០១ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

* * *

ប្រការ១ : អនុញ្ញាតអោយរោងម៉ាស៊ីនផលិតទឹកកកដើម ដែលមានលោកគួច សុផា ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ០០៦៧៣៣ភព ចុះថ្ងៃទី២៦-១០-៨៥ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ១០ ក្រុមទី១៦ សង្កាត់បឹងកេងកងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ បន្ត ដំណើរការផលិតកម្ម នៅក្នុងទីតាំងផ្ទះលេខ ១៣៩១ ផ្លូវជាតិលេខ២ ភូមិទួលរការ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១០២ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

* * *

ប្រការ១ : អនុញ្ញាតអោយសិប្បកម្មផលិតឥដ្ឋ-ក្បឿង ដែលមានលោកព្រុំ សុវណ្ណ ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ០៩២៣៩៣ ភព ចុះថ្ងៃទី២៧-៣-៨៥ ជាប្រធាន អាស័យដ្ឋាន បច្ចុប្បន្ន ភូមិជ្រោយអំពិល ឃុំក្បាលកោះ ស្រុកកៀនស្វាយ

ខេត្តកណ្តាល បន្តដំណើរផលិតកម្ម នៅ ក្នុងទីតាំងភូមិជ្រោយអំពិល ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

ប្រការ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណង
ឡើយ ។

* * *

ប្រកាសលេខ ១០៣ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

* * *

ប្រការ១ : អនុញ្ញាតអោយលោកយ៉ុន ភាព ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៥៨៩៦៧ ៣រ ចុះថ្ងៃទី២៩-១២-៨៨ អាសយដ្ឋានបច្ចុប្បន្ន ភូមិមោង ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១២០ សេះ នៅក្នុងទីតាំងភូមិមោង ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។

ប្រការ២ : លោក យ៉ុន ភាព ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
អ៊ិត ប្រាំង

* * *

ប្រកាសលេខ ១០៤ ឧក.ប្រក ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

* * *

ប្រការ១ : អនុញ្ញាតអោយក្រុមហ៊ុនអន្តរជាតិខេមអូ (CAMEO INTERNATIONAL Co, LTD) តំណាងដោយលោកជា ប៉ុង ពីនជាតិខ្មែរ សញ្ញាតិកម្ពុជា ភេទប្រុស អាយុ ៤៣ឆ្នាំ អាស័យដ្ឋាន ផ្ទះលេខ ៥៣២ ក្រុមទី៣២ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ កាន់អត្តសញ្ញាណប័ណ្ណ លេខ ៣០៣៧១៩ ភព ចុះថ្ងៃទី១០-១១-៩២ «បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ» ដែលមានឈ្មោះថា «រោងចក្រកាត់ដេរអន្តរជាតិ ខេមអូ» ក្នុងបរិវេណរោងចក្រ C7 ដែលអាគទីតាំង នៅភូមិដំណាក់ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ២ : ការសាងសង់ និងរៀបចំគ្រឿងចក្រត្រូវធ្វើទៅតាមប្លង់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែនិងថាមពល អោយបានសំរេចក្នុងរយៈពេល៦ខែ ដោយរាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។

ប្រការ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណ ភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្មរ៉ែ និងថាមពល អំពីស្ថាន ភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយផលិតនូវ «សំលៀកបំពាក់» ទៅតាមគំរូដែលតំកល់ទុក នៅក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ៥ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសផុតផ្ទុយ នឹងប្រការណាមួយដែលបាន ចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១០៥ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

* * *

ប្រការ១ : អនុញ្ញាតអោយក្រុមហ៊ុនសំហាន ខេមបូឌា ហ្វ៊េប្រ៊ិក (SAM-HAN CAMBODIA FABRIC CO LTD) តំណាងដោយលោក KIM DO SAM សញ្ជាតិកូរ៉េ ភេទប្រុស អាយុ៥៦ឆ្នាំ អាស័យដ្ឋាន NON HYUN JAE IL BLDG 2 nd FLOOR NO 58-2 NON HYUN DONG GANG NAM GU SEOUL

KOREA កាន់លិខិតឆ្លងដែនលេខ ២៥២៦៩៧៣ ចុះថ្ងៃទី១៨-៧-៨៩ «បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ» ដែលមានឈ្មោះថា «សំហានខេមបូឌា ហ៊ែប្រ៊ិក» មានទីតាំងស្ថិតនៅភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ២ : ការបង្កើតរោងចក្រនេះ ត្រូវធ្វើទៅតាមប្លង់និងគំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ ដែលបានតំកល់ទុកនៅក្រសួង ឧស្សាហកម្មរ៉ែនិងថាមពល ។

ប្រការ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្មរ៉ែ និងថាមពល អំពីស្ថានភាព ដំណើរការផលិតកម្មរបស់រោងចក្រ ។

ប្រការ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយផលិតគ្រឿង «សំលៀកបំពាក់» [illegible] តំកល់ទុក នៅក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ៥ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសលក្ខខណ្ឌ តាមប្រការណាមួយដែលបាន[illegible] លើប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១០៦ ឧក.ប្រក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

* * *

ប្រការ១ : អនុញ្ញាតអោយក្រុមហ៊ុន ជូស៊ីង ហ្គាមិន (ខេមបូឌា) អែលធីឌី (CHU HSING GAMENT (CAMBODIA) Co., LTD) តំណាងដោយលោក CHEN RON MING សញ្ជាតិតៃវ៉ាន់ ភេទប្រុស អាយុ ៤២ឆ្នាំ អាស័យដ្ឋាន 12 F-2 , N 51, SEC 2 , TAIPEI, TAIWAN, ROC កាន់ លិខិតឆ្លងដែនលេខ M11421354 ចុះថ្ងៃទី០៨-១២-៩៥ «បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំ ចេញ» ដែលមានឈ្មោះថា «រោងចក្រ ជូ ស៊ីង ហ្គាមិន» មានទីតាំងស្ថិតនៅភូមិខ្វរ ផ្លូវជាតិលេខ ៦អា សង្កាត់ព្រែកលាប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ២ : ការបង្កើតរោងចក្រនេះ ត្រូវធ្វើទៅតាមប្លង់និងគំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រកាត់ ដេរសំលៀកបំពាក់ ដែលបានតំកល់ទុកនៅក្រសួង ឧស្សាហកម្មរ៉ែនិងថាមពល ។

ប្រការ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណ ភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្មរ៉ែ និងថាមពល អំពីស្ថាន ភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយផលិតនូវ «សំលៀកបំពាក់គ្រប់ប្រភេទ » ទៅតាមគំរូ ដែលតំកល់ទុក នៅក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ៥ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរ នឹងប្រការណាមួយដែលបានចែងខាងលើប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហាងឆេងខា និងក្រោ

ពូ សុធីរៈ

* * *

៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ០៣៨ សសរ.កសក

ស្តីពីការបង្កើតគណៈកម្មការរៀបចំផែនការនយោបាយទឹកកសិកម្ម

ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៧

* * *

_ បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_ បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាព រាជរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតទិវាឧបោសថយទឹកកសិកម្ម
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សម្រេច

ប្រការ ១ : តែងតាំងគណៈកម្មការមួយដែលមានសមាសភាពដូចខាងក្រោម ÷

១_លោក វេង សាខុន អគ្គនាយករង នៃអគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រ ជាប្រធាន

២_លោក នួន ស៊ិន ប្រធាននាយកដ្ឋានចាត់តាំង ជាអនុប្រធាន

៣_លោក លួង គីមចេ៉ា ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ជាសមាជិក

៤_លោក គិត សេង អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ ជាសមាជិក

៥_លោក ខឹម ចិន្តា អនុប្រធានមន្ទីរក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ជាសមាជិក

៦_លោក ប៊ុន ហ៊ាន អនុប្រធាននាយកដ្ឋានវិស្វកម្ម នៃអគ្គនាយកដ្ឋានធារាសាស្ត្រឧតុនិយម និង ជលសាស្ត្រ អនុប្រធាន

៧_លោក ព្រហ្ម សារឿន អនុប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ ហិរញ្ញវត្ថុ នៃអគ្គ នាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រ ជាសមាជិក

៨_លោក គង់ បូ ប្រធានការិយាល័យចាត់តាំងមន្ទីរ ជាសមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ចរៀបចំធ្វើរបាយការណ៍សុន្ទរកថា និង សង់វេទិការ ព្រមទាំងសហការជាមួយគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និង អន្តរជាតិ អាជ្ញាធរខេត្ត ដើម្បីរៀបចំដំណើរការងារនេះអោយសម្រេចបានលទ្ធផលល្អប្រសើរ ។

ប្រការ ៣ : អគ្គនាយក ប្រធានខុទ្ទកាល័យ អគ្គនាយករងអគ្គនាយកដ្ឋានរដ្ឋបាលសាមញ្ញ នយោបាយ និង សាស្ត្រ ប្រធាននាយកដ្ឋានបាត់តាំង ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាន ផែនការ ស្ថិតិ និង លោក អ្នកមានឈ្មោះក្នុងប្រការ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
អនុរដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
តាវ់ សារ៉ាន

៤_និស្ថិការដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ០២ ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ០៦៧ ស.ក១.សសរ.

ឧបនាយករដ្ឋមន្ត្រី_រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១_ ១១ _ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤ ៩០ ចុះថ្ងៃទី ៣១_១០_១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសេចក្តីសំរេច លេខ ១៥១ ស.ក១.សសរ ចុះថ្ងៃទី ១៧.០៧.១៩៩៧ របស់ក្រសួង
- យោងតាមកិច្ចការចាំបាច់របស់ក្រសួង

សម្រេច

ប្រការ ១ : តែងតាំងសមាសភាពបន្ថែមក្នុងគណៈកម្មការ ដើម្បីសិក្សាស្រាវជ្រាវនិងផ្តល់យោបល់លើឯកសារ Preliminary Design Audit ព្រមជាមួយ Detailed Programme, General Plan, Preliminary Design និង ពង្រាងកិច្ចសន្យាបន្ថែម ស្តីពីការសាងសង់ ព្រលានយន្តហោះអន្តរជាតិពោធិ៍ចិនតុង :

១_លោក សុខ ពុធយឿន ប្រធាននាយកដ្ឋាន វិស្វកម្មព្រលានយន្តហោះ សមាជិក

២_លោក ស៊ុន ពាន់ធុណ ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច

អគ្គនាយកដ្ឋាន ស៊ីវិល សមាជិក

ប្រការ២ : លោកនាយកខុទ្ទកាល័យ ក្រសួងសាធារណការ និង ដឹកជញ្ជូន និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តរៀងៗខ្លួនតាមខ្លឹមសារ នៃសេចក្តីសម្រេចនេះ ចាប់ពីពេលចុះហត្ថលេខាតទៅ ។

ជ.នាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

ហត្ថលេខា និងត្រា

អ៊ឹង គៀត

* * *

៥_ទីស្តីការរដ្ឋមន្ត្រីក្រសួងព័ត៌មាន

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ០២៩ ៩៧ ពម.ប្រក

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រា ទី ៤១

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ _ ១១ _ ១១៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស.រកម ០៨៩៥_០៧ ចុះថ្ងៃទី ០១_៩_ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងពត៌មាន មានលេខ ៨៨៩ ៩៣ ឃព ចុះថ្ងៃទី ១១.១១. ១៩៩៣ ស្តីពីការអនុញ្ញាតអោយកាសែត «ដំណឹងល្អ» ចេញផ្សាយ
- បានឃើញសំណើសុំប្តូរឈ្មោះពីកាសែត «ដំណឹងល្អ» មកទស្សនាវដ្តី «ប្រិយមិត្ត» របស់លោក ចាន់ វ៉ែន ចុះថ្ងៃទី ០៤.១២.១៩៩៦

សម្រេច

ប្រការ ១ : អនុញ្ញាតអោយចេញផ្សាយទស្សនាវដ្តី «ប្រិយមិត្ត» បោះពុម្ពចែកផ្សាយដោយមានលោក ចាន់ វ៉ែន ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការលេខ ៣៨ ផ្លូវ ៣៦៤ សង្កាត់ទួលស្វាយព្រៃ ខ័ណ្ឌចំការមន ភ្នំពេញ ។

ក្នុងករណីមានការផ្លាស់ប្តូរចំណុចណាមួយក្នុងអត្តសញ្ញាណ នៃទស្សនាវដ្តីរបស់ខ្លួនត្រូវ ជូនដំណឹងជាមុន ៥ ថ្ងៃ មកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : ប្រកាសលេខ ៨៨៩ / ៩៣ ឃព ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ របស់ក្រសួងពត៌មាន ស្តីពីការអនុញ្ញាតអោយកាសែត «ដំណឹងល្អ» ចាត់ទុកជានិរាករណ៍ ។

រាល់ដំណើរការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌អ្នកសារពត៌មាន ច្បាប់ស្តីពីរបបសារពត៌មាន និងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង ត្រូវប្រគល់ទស្សនាវដ្តីចំនួន ៦ ច្បាប់រៀងរាល់លេខ ចេញផ្សាយមកតំកល់ទុកជាឯកសារ នៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តិល្មើស អំពីសេចក្តីដូចមានចែងក្នុងប្រការ ១ និង ប្រការ២ ខាងលើសាម៉ី ខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និង លោកចាងហ្វាងទស្សនាវដ្តី «ប្រិយមិត្ត» ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ មានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និង ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ហត្ថលេខា
ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ០៣០ ពត ពម.ប្រក

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រា ទី ៤១
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ – ១១ – ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ ស្តីពីរបបសារព័ត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស.រកម ០៨៩៥–០៧ ចុះថ្ងៃទី ០១–៩–១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងព័ត៌មាន មានលេខ ២៥១/៩៥ ពម.ប្រក ចុះថ្ងៃទី ០៥–១០–១៩៩៥ ស្តីពីការអនុញ្ញាតអោយកាសែត «យុត្តិធម៌» ចេញផ្សាយ
- បានឃើញសំណើសុំចេញផ្សាយបន្តកាសែត «យុត្តិធម៌» ឡើងវិញរបស់លោក វង់ សារឿន ចុះថ្ងៃទី ២៧.១១.១៩៩៦

សម្រេច

ប្រការ ១ : អនុញ្ញាតអោយកាសែត «យុត្តិធម៌» បន្តការចេញផ្សាយរបស់ខ្លួនឡើងវិញដោយមានលោក វង់ សារឿន ជាថាងហ្វាងការផ្សាយ ។ ទីស្នាក់ការលេខ ១០៦ ផ្លូវ ៣៦០ សង្កាត់ទួលស្វាយព្រៃទី ២ ខ័ណ្ឌចំការមន ភ្នំពេញ ។

ក្នុងករណីមានការផ្លាស់ប្តូរចំណុចណាមួយក្នុងអត្តសញ្ញាណ នៃកាសែតរបស់ខ្លួនត្រូវជូនដំណឹងជាមុន ៥ ថ្ងៃ មកក្រសួងព័ត៌មាន ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : ប្រកាសលេខ ២៥១ ៩៥ ពម.ប្រក ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការអនុញ្ញាតអោយកាសែត «យុត្តិធម៌» ចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ ក្រមសីលធម៌អ្នកកាសែត, ច្បាប់ស្តីពីរបបសារពត៌មាននិងច្បាប់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា រួចត្រូវប្រគល់កាសែត ចំនួន ០៦ ច្បាប់ រៀងរាល់លេខ ចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤ : ក្នុងករណីប្រព្រឹត្តិល្មើស អំពីសេចក្តីដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះ សាមីខ្លួន ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និង លោកចាងហ្វាងកាសែត «យុត្តិធម៌» ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៦ : ប្រកាសនេះ មានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និង ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ០៣២ ៩៧ ព.ម.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ប្រកាសអោយប្រើប្រាស់ច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ ០១៩៦-១៤ នស រកម ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសប្រើប្រាស់បង្កើតពតិមាន
- ពិនិត្យលក្ខណៈសម្បត្តិ មន្ត្រីរាជការ

សម្រេច

ប្រការ ១ :-តែងតាំងមន្ត្រីរាជការចំនួន ០២ រូប ជាថ្នាក់អធិការរង នៃអគ្គាធិការដ្ឋានក្រសួង ពត៌មាន ដូចមានរាយនាមខាងក្រោម ÷

១-លោក ឈឿន ណារិទ្ធ ជាអធិការរង ទទួលបន្ទុកការងាររៀបចំផែនការ អធិការកិច្ច

២-លោក ម៉ុ កិន ជាអធិការរងទទួលបន្ទុក ការងារអង្កេតស្រាវជ្រាវ

ប្រការ ២ : ឯកឧត្តម អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ លោក អគ្គាធិការរង លោកអគ្គនាយកនៃអគ្គនាយកដ្ឋានចំណុះក្រសួង លោកប្រធាននាយក ដ្ឋានបុគ្គលិក លោកនាយកប្រធានផែនការគណនេយ្យ ហិរញ្ញវត្ថុ និង សាម៉ីខ្លួន ដូច ក្នុងប្រការមួយត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

អៀង មូលី

* * *

៦_នីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ប្រកាស

ភ្នំពេញ,ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ០៦ ប្រក.មស ៩៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌ ដែលប្រកាសអោយប្រើអោយប្រើដោយ ព្រះរាជក្រមលេខ នស.រកម.០១៩៦.០៤
- បានឃើញច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជាដែល បានប្រកាសអោយប្រើ ដោយក្រឹត្យលេខ ០៦.ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣
- បានឃើញពាក្យសុំផ្ទេររបស់លោក ហុង សុធី ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

សំរេច

មាត្រា ១ : លោក ហុង សុធី ជាក្រឡាបញ្ជីបំរើការងារនៅតុលាការខេត្តស្វាយរៀង ត្រូវបាន ផ្ទេរអោយទៅបំរើការងារនៅតុលាការខេត្តកណ្តាល ។

មាត្រា២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថមផ្សេងៗ ត្រូវបានបើកនៅតុលាខេត្តកណ្តាលបន្ទាប់ ពីបានផ្តាច់ចេញពីបញ្ជីបើកប្រាក់របស់តុលាការខេត្តស្វាយរៀង ។

មាត្រា៣ : តុលាការខេត្តស្វាយរៀង តុលាការខេត្តកណ្តាល នាយកដ្ឋានបុគ្គលិក និង បណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌និងសាមីខ្លួន ត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ចែម ស្ងួន

* * *

ភ្នំពេញ, ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ០៨ ប្រក.បបប.៩៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌ដែលប្រកាសអោយប្រើដោយព្រះរាជក្រឹត្យលេខ នស.រកម ០១៩៦.០៤
- បានឃើញច្បាប់ស្តីពីការរៀបចំតាំងនិងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលមានប្រកាសអោយប្រើដោយលេខ ០៦.ក្រ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ១៩៩៣

សំរេច

មាត្រា ១ :– លោក គាត សុភាក់ ក្រឡាបញ្ជីតុលាការខេត្តកំពត ត្រូវបានផ្ទេរអោយទៅបំរើការងារនៅតុលាការខេត្តកណ្តាល ។

មាត្រា ២ :–ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ ត្រូវបានបើកនៅអង្គភាពថ្មី បន្ទាប់ពីបានផ្តាច់ចេញពីអង្គភាពដើម ។

មាត្រា៣ : –នាយកដ្ឋានបុគ្គលិកនិងបណ្តុះបណ្តាល ក្រសួងយុត្តិធម៌ តុលាការខេត្តកំពត តុលាការខេត្ត កណ្តាលនិងសាមីខ្លួន ត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ចែម ស្ងួន

* * *

ភ្នំពេញ, ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ១០ ប្រក.ម.មប៩៧

ភ្នំពេញ ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

* * *

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស.រកម ០១៩៦.០៤ .

- បានឃើញច្បាប់ស្តីពីការរៀបចំនិងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជាដែលបានប្រកាសអោយប្រើដោយក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣
- បានឃើញលិខិតលេខ ៤៣ រប ១៨.៩៧ របស់តុលាការខេត្តកំពង់ឆ្នាំង ចុះថ្ងៃទី ១០ មករា ឆ្នាំ ១៩៩៧ ស្តីពីការសុំតែងតាំងលោក ចាន់ សុភាព ជាក្រឡាបញ្ជី
- តាមសំណើរបស់នាយកដ្ឋានបុគ្គលិក និង បណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌

សំរេច

មាត្រា ១: –តែងតាំងលោក ចាន់ សុភាព បច្ចុប្បន្នបុគ្គលិកបំរើការងារនៅតុលាការខេត្តកំពង់ឆ្នាំង ជាក្រឡាបញ្ជីតុលាការខេត្តកំពង់ឆ្នាំង ។

មាត្រា ២ :–តុលាការខេត្តកំពង់ឆ្នាំង នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌ និងសាមីម្នាក់ មានភារកិច្ចអនុវត្តប្រកាសនេះ តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ចែម ស្ងួន

* * *

៧_នីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

ប្រកាស

ភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ១១៩ អយក.ប្រក

ស្តីពីការអនុញ្ញាតបើកសាលាបឋមសិក្សា សម្តេចឪពុកព្រះនរោត្តម រណឫទ្ធិ រាជានុកូល ក្នុងដែនដីសិក្សាខេត្ត ស្ទឹងត្រែង

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តមសីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១.១១.៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។

- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃ ២០.៧.៩៤
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តមសីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាលេខ នស.រកត ០៧៩៦-៥២ ចុះថ្ងៃទី២៦.៧.៩៦ ស្តីពីប្រពន្ធ័អប់រំចំណេះទូទៅ ១២ ឆ្នាំ
- បានឃើញលិខិតស្នើសុំរបស់ប្រធានមន្ទីរអប់រំ យុវជននិងកីឡាខេត្តស្ទឹងត្រែងលេខ ១៣ អយក.ស ចុះថ្ងៃទី២៤ មេសា ១៩៩៦ និងចំណារឯកភាពរបស់ឯកឧត្តម លី ស្វ អភិបាលខេត្តស្ទឹងត្រែង លេខ ៦៣៩ សណន ចុះថ្ងៃទី៣០_៤_៩៦
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សម្រេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង បើកសាលាបឋមសិក្សាថ្មីមួយកន្លែង ដែលទីតាំងស្ថិតនៅភូមិ រាជានុកូល ឃុំ ស្ទឹងត្រែង ស្រុក ស្ទឹងត្រែង ខេត្តស្ទឹងត្រែង ជាផ្លូវការក្នុងផែនទីសិក្សារបស់ខេត្តស្ទឹងត្រែង ចាប់ពីឆ្នាំសិក្សា ១៩៩៦–៩៧ នេះតទៅ ។

ប្រការ ២ : សាលាបឋមសិក្សាថ្មីនេះមានឈ្មោះថា សាលាបឋមសិក្សា សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** រាជានុកូល ។

ប្រការ ៣ : សាលាបឋមសិក្សា សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ រាជានុកូល ត្រូវដឹកនាំដោយនាយកដ្ឋាន ១ រូប និងនាយករងព្រមទាំងបុគ្គលិកផ្សេងៗ តាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

ប្រការ ៤: នាយក និងនាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច តាមគោលការណ៍កំណត់របស់រដ្ឋ ។

ប្រការ ៥: បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ៦: ប្រធានមន្ទីរក្រសួងអប់រំ យុវជន និង កីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋាន ផែនការ ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្តស្ទឹងត្រែង ប្រធានការិយាល័យអប់រំស្រុក

ស្ទឹងត្រែង នាយកសាលា បឋមសិក្សា សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ រាជានុកូល មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

គា សារឿន

* * *

ភ្នំពេញ, ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ១២០ អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា ឧត្តមសមាគម មកជា

សាលាបឋមសិក្សា ម៉ុន រ៉េតី.ម៉ុក ម៉ែន ឧត្តមសមាគម»

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តមសីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រ កម្ពុជា ចុះថ្ងៃទី ០១/១១/៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០/៧/៩៤
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រ កម្ពុជាលេខ សន.រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦/៧/៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ ឆ្នាំ
- បានឃើញលិខិតស្នើសុំរបស់ គណៈកម្មការសាងសង់ សាលាបឋមសិក្សាឧត្តមសមាគម ចុះថ្ងៃ ទី ២៨/៥/៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ ឆ្នាំ
- បានឃើញលិខិតស្នើសុំរបស់គណៈកម្មការសាងសង់ សាលាបឋមសិក្សាឧត្តមសមាគម ចុះថ្ងៃទី ២៨/៥/៩៦ ដោយមានចំណារឯកភាពរបស់ឯកឧត្តមអភិបាលខេត្ត ព្រៃវែង លេខ១៣៧/៩៦រប ចុះថ្ងៃទី ០៥/៧/៩៦
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និងមត្តេយ្យសិក្សា

សំរេច

ប្រការ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង ប្តូរឈ្មោះ សាលាបឋមសិក្សា ឧត្តមសមាគម" ដែលមានទីតាំងស្ថិតនៅឃុំ ព្រែកខ្សាយ ស្រុកពាមរក៍ ខេត្តព្រៃវែង សាលាបឋមសិក្សាមកជា"ប៊ុនរ៉ានី ហ៊ុន សែន ឧត្តមសមាគម" វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៦-៩៧ នេះតទៅ ។

ប្រការ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជា និរាករណ៍ ។

ប្រការ៣ : ប្រធានមន្ទីរក្រសួងអប់រំ យុវជននិងកីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង ប្រធានការិយាល័យអប់រំស្រុកពាមរក៍ នាយកសាលាបឋមសិក្សា"ប៊ុនរ៉ានី ហ៊ុនសែន ឧត្តមសមាគម" មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

គា សាហាន

* * *

ភ្នំពេញ, ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ: ១២៧ អយក.ប្រក

ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅរូបវិទ្យា

" សំរាប់សិស្សថ្នាក់ទី ៨ "

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តមសីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១/១១/៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៩០ ចុះថ្ងៃ ៣១ ខែ តុលា ឆ្នាំ១៩៩៤ កែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជននិងកីឡា
- បានពិនិត្យលិខិតឆ្លងឆ្លៀសនាម លេខ ៣១៨ អយក.ឆុទន ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំ យុវជននិងកីឡា ស្តីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធអប់រំ
- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅរូបវិទ្យាថ្នាក់ទី ៨ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៧

សំរេច

ប្រការ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅរូបវិទ្យាសំរាប់សិស្សថ្នាក់ទី៨ ដែលជាស្នាដៃនិពន្ធរបស់គណៈកម្មការរូបវិទ្យាមធ្យមសិក្សា នៃវិទ្យាស្ថានស្រាវជ្រាវ ក្រសួងអប់រំយុវជននិងកីឡា និងរៀប រៀងដោយលោក ស៊ឹម ចាន់ ធី ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំនេះទូទៅ ។

ប្រការ២ : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយ បណ្ណាល័យ នាយកដ្ឋានចំណេះទូទៅនិង មត្តេយ្យសិក្សា មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

តុល ឡោះ

* * *

៨_ទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ: ០២៨ បទប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេច **នរោត្តមសីហនុវរ្ម័ន** ចុះថ្ងៃទី ០១ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦ នស. ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ១៩៩៥
- បានឃើញព្រះរាជក្រមស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល លេខ ០៦ន.ស៩៤ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស–រកម ០១៩៦-២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ប្រកាស អោយប្រើដោយច្បាប់ស្តីពីបង្កើត ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ១៩៩៤ និងប្រកាសអោយប្រើ នៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញសំណូមពររបស់នាយកដ្ឋានផែនការហិរញ្ញវត្ថុ និងពិនិត្យសមត្ថភាពមន្ត្រីបុគ្គលិករាជការ

សម្រេច

ប្រការ១ : តែងតាំងមន្ត្រី បុគ្គលិក រាជការចំនួន ០៥ រូបនៅនាយកដ្ឋានផែនការហិរញ្ញវត្ថុ ដែលមានរាយនាមខាងក្រោមអោយទទួលតួនាទី និងភារកិច្ចដូចតទៅ :

១–លោក ប៉ាល់ វុឌ្ឍីកា ជាអនុប្រធាននាយកដ្ឋានផែការ–ហិរញ្ញវត្ថុ

២–អ្នកស្រី អាន គឹមឈុន ជាប្រធានការិយាល័យហិរញ្ញកិច្ច

៣–លោក ម៉ៅ ភក្ក ជាអនុប្រធានការិយាល័យហិរញ្ញកិច្ច

៤–លោក អ៊ុក សុគន្ធ ជាប្រធានការិយាល័យរដ្ឋបាល

៥–លោក មៀង បូពន្ធ ជាអនុប្រធានការិយាល័យផែនការ–ស្ថិតិ

ប្រការ២: មន្ត្រីរាជការចំនួន ០៥ រូប ដូចមានចែងក្នុងប្រការ១ខាងលើត្រូវអនុវត្តតាមតួនាទីភារកិច្ច និងក្នុងសមត្ថកិច្ចរបស់ខ្លួន ។

ប្រការ៣: ខុទ្ទកាល័យ, អធិការដ្ឋាន, នាយកដ្ឋានផែនការគណនេយ្យ–ហិរញ្ញកិច្ច និងសាមីខ្លួនទាំង ០៥រូប ត្រូវទទួលបន្ទុកអនុវត្តន៍ តាមខ្លឹមសារនៃប្រកាសនេះ ។

ប្រការ៤: ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

បាន្តហត្ថលេខា និងត្រា

សូ យុន

* * *

៩_ទីស្ដីការក្រសួងធម្មការ និងសាសនា

សេចក្ដីសម្រេច

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

សេចក្ដីសម្រេចលេខ: ១៩/៩៧ កធស

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

– បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះ រាជក្រម លេខ ន.ស.រ.ក.ម ០១៩៦–១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។

- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាលេខ : ០៦ ន.ស១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ:៧២អ.ន.ក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ១៩៩២ ស្តីពីការរៀបចំនិង ប្រព្រឹត្តទៅនៃក្រសួងធម្មការនិងសាសនា
- បានឃើញពាក្យសុំបើក ស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយប្រូតេស្តង់ ក្រុមជំនុំមេត្រីភាពកម្ពុជា របស់លោកស្រី កេត ផល្លា ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩៦ ។
- លិខិតបញ្ជាក់ការយល់ព្រមអំពីទីតាំង របស់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញ លេខ: ៣៦៧០ល.ស.ស ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

សម្រេច

ប្រការ១ : អនុញ្ញាតជាគោលការណ៍អោយបើកស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយប្រូតេស្តង់ ក្រុមជំនុំមេត្រីភាពកម្ពុជា នៃព្រះវិហារហៅឈ្មោះ" ក្រុមជំនុំមេត្រីភាពពោធិចិនតុង" មួយកន្លែងដែលមានទីតាំងស្នាក់ការកណ្តាល ស្ថិតនៅផ្ទះលេខ ២៥៦ ផ្លូវមហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ កាកាប ខណ្ឌ ដង្កោ រាជធានីភ្នំពេញ ។

ប្រការ២ : ស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយប្រូតេស្តង់នៃព្រះវិហារឈ្មោះ" ក្រុមជំនុំមេត្រីភាពពោធិចិនតុង" ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនា គ្រិស្ទ ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ៣ : បរិស័ទទាំងអស់របស់ព្រះវិហារឈ្មោះ" ក្រុមជំនុំមេត្រីភាពពោធិចិនតុង" ត្រូវគោរព និង អនុវត្តន៍អោយបានត្រឹមត្រូវម៉ឺងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការនិងសាសនា ។ អ្នកដឹកនាំស្នាក់ការខាងលើនេះ ត្រូវម៉ាន់សាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អ ជាមួយស្ថាប័នពាក់ព័ន្ធសឡាជាជាប់ខាតមិនធ្វើអោយប៉ះពាល់ ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនា និង សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

ប្រការ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពី សេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ៥ : នាយកដ្ឋានសាសនា–មន្ទីរធម្មការ និងសាសនា រាជធានីភ្នំពេញ និង មន្ត្រីរាជការគ្រប់លំ ដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្តន៍សេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និងត្រា

ហៀង វណ្ណរ័ត្ន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ : ២០/៩៧ ក.ធ.ស

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជ ក្រមលេខ ន.ស.រ.ក.ម ០១៩៦–១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាលេខ : ០៦ ន.ស១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ:២២អ.ន.ក្រ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ១៩៩២ ស្តីពីការរៀបចំនិងប្រ ព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើក ស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត និកាយប្រូតេស្តង់ ក្រុមប្រិសបីតិរៀត របស់ លោក ពេជ ផាន់ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៦ ។
- លិខិតបញ្ជាក់ការយល់ព្រមអំពីទីតាំង របស់ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានី ភ្នំពេញ លេខ : ៤៤៦៤ ល.ស.ស ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៦

សំរេច

ប្រការ១ : អនុញ្ញាតជាគោលការណ៍អោយ បើកស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត និកាយប្រូតេស្តង់ ក្រុមប្រិសប៊ីតិរៀត នៃព្រះវិហារហៅឈ្មោះ " គ្រិស្តបរិស័ទគ្រប់ជនជាតិក្រុងភ្នំពេញ " មួយកន្លែង ដែលមានទីតាំងស្នាក់ការកណ្តាលស្ថិតនៅផ្ទះលេខ ០៩ ផ្លូវលេខ ១១៤ សង្កាត់ផ្សារថ្មីទី១ ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ ។

ប្រការ២ : ស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត និកាយប្រូតេស្តង់ នៃព្រះវិហាឈ្មោះ គ្រិស្តបរិស័ទគ្រប់ជនជាតិក្រុងភ្នំពេញ" ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិ សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ៣ : បរិស័ទទាំងអស់របស់ព្រះវិហារឈ្មោះ " គ្រិស្តបរិស័ទគ្រប់ជនជាតិក្រុងភ្នំពេញ" ត្រូវគោរពនិងអនុវត្តអោយបានត្រឹមត្រូវម៉ឺងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទ បញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា ។ អ្នកដឹកនាំស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គី និង ទំនាក់ទំនងអោយបានល្អ ជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើ អោយប៉ះពាល់ ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនា និង សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

ប្រការ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពី សេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ៥ : នាយកដ្ឋានសាសនា-មន្ទីរធម្មការ និងសាសនា រាជធានីភ្នំពេញ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្តន៍សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និងត្រា

ហៀង វណ្ណារ័ត្ន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

សេចក្តីសំរេច លេខ :២១/៩៧ ក.ធ.ស

ស្តីពីការអនុញ្ញាតអោយបើកជាបណ្តោះអាសន្ន

"ពុទ្ធិកសមាគម អភិវឌ្ឍន៍កម្ពុជា"

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងទី២ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរដ្ឋមន្ត្រី និង រដ្ឋលេខាធិការ នៃរាជរដ្ឋាភិបាល
- បានឃើញលិខិតស្នើសុំរបស់ «ពុទ្ធិកសមាគមន៍អភិវឌ្ឍកម្ពុជា» ចុះថ្ងៃទី ០១ ខែមករា ឆ្នាំ១៩៩៧

សំរេច

ប្រការ១ : អនុញ្ញាតជាបណ្តោះអាសន្នអោយបើក «ពុទ្ធិកសមាគមន៍អភិវឌ្ឍន៍កម្ពុជា»ដែលជាសមាគមមានលក្ខណៈពុទ្ធសាសនាសុទ្ធសាធ ។

ប្រការ២ : «ពុទ្ធិកសមាគមអភិវឌ្ឍន៍កម្ពុជា»ត្រូវគោរពអោយបានត្រឹមត្រូវតាមច្បាប់ នៃ ព្រះរាជាណាចក្រកម្ពុជា និង បទបញ្ញត្តិទាំងឡាយរបស់ក្រសួងធម្មការ និងសាសនា ។ សន្យាដាច់ ខាតមិនប្រព្រឹត្តផ្ទុយ និងលក្ខន្តិកៈ មិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនា និង សណ្តាប់ធ្នាប់សង្គម ។

ប្រការ៣ : «ពុទ្ធិកសមាគមអភិវឌ្ឍន៍កម្ពុជា» ត្រូវបំពេញបែបបទជាថ្មី នៅពេលដែលរដ្ឋសភាអនុម័ត «ច្បាប់ស្តីពីសមាគម» ។

ប្រការ៤ : រាល់ការអនុវត្តន៍ផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ៥ : នាយកដ្ឋានធម្មការ និងស្ថាប័ន្ន គ្រប់លំដាប់ថ្នាក់ដែលមានការពាក់ព័ន្ធ ត្រូវសហការ អនុវត្តន៍ សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ៦ : សេចក្តីសំរេចនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះ ។

ហត្ថលេខា និងត្រា

ហៀង ឧណ្ណរ័ត្ន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ : ២៣ ៩៧ កធស.ប្រក

* * *

រដ្ឋលេខាធិការ ក្រសួងធម្មការ និង សាសនា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣
- បានឃើញ ព្រះរាជក្រម លេខន.ស.រកម ០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងធម្មការនិងសាសនា
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការ ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ ១៩៤ ន.ស ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤
- បានឃើញ អនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ១៩៩២ ដែល រៀបចំនិងប្រ ព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា
- បានឃើញប្រកាសលេខ ១៨១-៩៦ កធស ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ១៩៩៦
- អនុលោមតាមការងារចាំបាច់របស់ក្រសួង

សំរេច

ប្រការ១ : តែងតាំងលោក ទេព-ធន បច្ចុប្បន្ន អនុប្រធានមន្ទីរធម្មការ និង សាសនា ជាប្រធាន មន្ទីរធម្មការនិងសាសនា ជំនួសលោក មោក ស៊ីម ដែលដាក់អោយចូលនិវត្តន៍ មានប្រភេទ កាំប្រាក់ ក២-៧.១ ។

ប្រការ២ : បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗប្រគល់ជូនមន្ទីរធម្មការនិងសាសនា ខេត្តស្វាយរៀងជា អ្នកចាប់រង និង រៀបចំ ។

ប្រការ៣ : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញកិច្ច មន្ទីរផែនការ មន្ទីរហិរញ្ញវត្ថុខេត្ត ស្វាយរៀង និង លោក ទេព-ធន ត្រូវអនុវត្តតាមប្រកាសនេះរៀងៗខ្លួន ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ហៀន វណ្ណហ៊ន

* * *

បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៤០០ ក្បាល

តម្លៃ ១៣៥០ រៀល